# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៦ ខែ មិនា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៥៧,៤៩៤ ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារវិទ្យាសាស្ត្រ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ)រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន ៥៧,៤៩៤ ដុល្លារអាមេរិក ដល់សាលាគរុកោសល្យ និងវិក្រឹតការខេត្តកណ្តាល សម្រាប់គម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តកណ្តាល ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយលោក កាវ៉ាម្យ៉ា ហ៊ីរ៉ូស៊ី ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោកស្រី ឈិន សុវណ្ណ នាយិកាសាលាគរុកោសល្យ និងវិក្រឹតការខេត្តកណ្តាលនៅស្ថានទូតជប៉ុន។

ដើម្បីផ្តល់ការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រឲ្យកាន់តែប្រសើរឡើង សាលាគរុកោសល្យ និងវិក្រឹតការខេត្តកណ្តាល នឹងអនុវត្តគម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រមួយខ្នងកម្ពស់មួយជាន់ សម្រាប់គរុសិស្ស២៤០នាក់ដែលនឹងក្លាយជាគ្រូបង្រៀនបឋមសិក្សានៅក្នុងខេត្តកណ្តាលបន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល។ ជាផ្នែកមួយនៃគម្រោងនេះផងដែរ បរិក្ខារសិក្សាដែលមានដូចជាតុ និងកៅអីពិសោធន៍ ធ្នើដាក់សម្ភារៈពិសោធន៍ ក៏នឹងត្រូវបំពាក់ជូនផងដែរ។ យើងរំពឹងថា សិស្សានុសិស្សបឋមសិក្សាប្រមាណ១៨០,០០០នាក់នៅក្នុងខេត្តនឹងអាចទទួលបានការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រកាន់តែប្រសើរឡើងពីលោកគ្រូ អ្នកគ្រូ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៧លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៦៩គម្រោងនៅទូទាំងប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*